ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងរដ្ឋប្បវេណីលេខៈ ៨៩២
ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០
សាលក្រមលេខៈ ០២១ (ថ)
ចុះថ្ងៃទី០៣/០៦/២០២១

# តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្ដាលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០២១

## សមាសភាពជំនុំជម្រះ

- លោក **ថោង ផល្លាវឌី** ចៅក្រមសាលាដំបូងខេត្តកណ្ដាល
- លោក **ហ៊ុំ សារ៉ាឌុង** ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

-ដើមចោទឈ្មោះ [redacted] សម្បត្តិ ភេទស្រី កើតឆ្នាំ១៩៦៧ មានទីលំនៅបច្ចុប្បន្ន [redacted]

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

-ចុងចម្លើយឈ្មោះ [redacted] មឿន ភេទស្រី កើតឆ្នាំ១៩៨០ មានទីលំនៅបច្ចុប្បន្ន [redacted]

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

## អង្គហេតុ និង ចំណុចវិវាទ

១-សាលក្រមដែលទាមទារដោយដើមចោទ

ដើមចោទប្ដឹងសុំឱ្យតុលាការចេញសាលក្រមតាមការទាមទាររបស់ខ្លួនដូចខាងក្រោមៈ

១-១ បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] មឿន ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលមកឱ្យដើមចោទឈ្មោះ [redacted] សម្បត្តិ នូវអចលនវត្ថុដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ ដែលមានទីតាំងស្ថិតនៅភូមិឈើនាង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។

១-២ បញ្ជាក់ថា ឈ្មោះ [redacted] សម្បត្តិ ពិតជាម្ចាស់កម្មសិទ្ធិលើដីមួយកន្លែងដែលមានទីតាំងស្ថិតនៅភូមិឈើនាង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល មានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ ដោយផ្អែកលើកិច្ចសន្យាលក់ផ្ដាច់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥។

១-៣ ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

២-ការពន្យល់ត្រួសៗ អំពីរឿងក្ដី

រឿងក្ដីនេះ ជារឿងក្ដីដែលដើមចោទឈ្មោះ [redacted] សម្បត្តិ ប្ដឹងសុំឱ្យតុលាការចេញសាលក្រម បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] មឿន ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលមកឱ្យដើមចោទឈ្មោះ [redacted] សម្បត្តិ នូវអចលនវត្ថុដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ ដែលមានទីតាំងស្ថិតនៅភូមិឈើនាង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ហើយបញ្ជាក់ថា ឈ្មោះ [redacted]



Scanned with CamScanner

សម្បត្តិ ពិតជាម្ចាស់កម្មសិទ្ធិលើដីមួយកន្លែងដែលមានទីតាំងស្ថិតនៅភូមិឈើនាង ឃុំគោកគ្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល មានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ ដោយផ្អែកលើកិច្ចសន្យាលក់ផ្ដាច់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥ និងប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥ ដើមចោទបានទិញដីពីរកន្លែងពីឈ្មោះ [redacted] មឿន ដែលមានទីតាំងស្ថិតនៅភូមិឈើនាង ឃុំគោកគ្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលមានវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ ដោយមានកិច្ចសន្យាលក់ផ្ដាច់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥។ ហើយនៅពេលដែលដើមចោទទិញដីនេះរួចហើយ គឺដើមចោទ និងឈ្មោះ [redacted] មឿន មិនបានធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិទៅតាមច្បាប់នោះទេ គឺគ្រាន់តែធ្វើកិច្ចសន្យាលក់ផ្ដាច់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥ តែប៉ុណ្ណោះ។

៣-ចំណុចវិវាទ និងចំណុចគ្មានវិវាទ

៣-១ ចំណុចវិវាទ:

តើចុងចម្លើយពិតជាបានលក់ដីទាំងពីរកន្លែង ដែលមានវិញ្ញាបណ្ណបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបណ្ណបត្រសម្គាល់ម្ចាស់អចលនវត្ថុមួយទៀត លេខ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ ដែលមានទីតាំងនៅភូមិឈើនាង ឃុំគោកគ្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ទៅឱ្យដើមចោទឈ្មោះ [redacted] សម្បត្តិ ពិតប្រាកដមែនដែរ ឬទេ?

៣-២ ចំណុចគ្មានវិវាទ: គ្មាន។

៤-ការអះអាងរបស់គូភាគី

៤-១ ការអះអាងរបស់ដើមចោទ

-ដើមចោទឈ្មោះ [redacted] សម្បត្តិ ធ្វើសេចក្ដីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទីមួយថា ខ្លួនស្នើសុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម៖

ក.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] មឿន ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលមកឱ្យខ្លួន នូវអចលនៈវត្ថុដែលមានវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ ដែលមានទីតាំងស្ថិតនៅភូមិឈើនាង ឃុំគោកគ្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។

ខ.បញ្ជាក់ថា ខ្លួនគឺជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុជាដីពីរកន្លែង ដែលមានវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ ដោយផ្អែកលើកិច្ចសន្យាលក់ផ្ដាច់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥។

ចំពោះអង្គហេតុដែលជាមូលហេតុនៃការទាមទារចំណុចទី១ ៖ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥ ខ្លួនបានទិញដីពីរកន្លែងពីឈ្មោះ [redacted] មឿន ដែលមានទីតាំងស្ថិតនៅភូមិឈើនាង ឃុំគោកគ្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដែលមានវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា



Scanned with CamScanner

ឆ្នាំ២០០៥ ដោយមានកិច្ចសន្យាលក់ផ្ដាច់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥។ ហើយនៅពេលដែលខ្លួនទិញដីនេះរួចហើយ គឺខ្លួន និងឈ្មោះ [redacted] មឿន មិនបានធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិទៅតាមច្បាប់នោះទេ គឺគ្រាន់តែធ្វើកិច្ចសន្យាលក់ផ្ដាច់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥ តែប៉ុណ្ណោះ។

-ដើមចោទឈ្មោះ [redacted] សម្បត្តិ ធ្វើសេចក្ដីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទីពីរថា ខ្លួននៅតែរក្សាការអះអាង និងការទាមទារដូចក្នុងកំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផលលើកទី១ កាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១ ទុកនៅដដែរ។

-ដើមចោទឈ្មោះ [redacted] សម្បត្តិ ធ្វើសេចក្ដីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទីបីថា ខ្លួននៅតែរក្សាការអះអាង និងការទាមទារដូចក្នុងកំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផលលើកទី២ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ទុកនៅដដែរ។ ចំពោះការដែលលោកមេធាវីចុងចម្លើយ អះអាងថា ដីនោះគឺឈ្មោះ [redacted] ផល្លិកា ជាអ្នកយកទៅលក់ ឈ្មោះ [redacted] មឿន មិនបានដឹងទេ គឺមិនពិតទេពេលនោះគឺឈ្មោះ [redacted] ផល្លិកា និងឈ្មោះ [redacted] មឿន ទៅទាំងពីរនាក់។ ហើយចំពោះការដែលមេធាវីចុងចម្លើយ អះអាងថា ក្នុងកិច្ចសន្យាលក់ផ្ដាច់មានដីតែមួយប្លង់ទេ គឺមិនពិតទេ គឺមានកិច្ចសន្យាលក់ផ្ដាច់ពីរ មានក្បាលដីខុសគ្នា គឺវិញ្ញាបណ្ណបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបណ្ណបត្រសម្គាល់ម្ចាស់អចលនវត្ថុមួយទៀតលេខ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ ។ មួយទៀតចំពោះមេធាវីចុងចម្លើយស្នើសុំបង្អង់នីតិវិធី ដោយសាររឿងនេះជារឿងព្រហ្មទណ្ឌ ខ្លួនសុំឱ្យតុលាការបន្តនីតិវិធី។ ចំពោះកិច្ចសន្យាលក់ផ្ដាច់នោះមិនមានចុះចំនួនទឹកប្រាក់ ព្រោះម្ដាយមីងខ្លួនឈ្មោះ [redacted] មឿន មិនឱ្យចុះចំនួនទឹកប្រាក់ ដោយសារគាត់ថាមិនបាច់ចុះទឹកប្រាក់ទេ គាត់លក់ហើយមិនយកវិញ គាត់ប្រគល់ប្លង់ឱ្យ តែដោយសារប្អូនគាត់ឈ្មោះ [redacted] ម៉ាង ថាធ្វើកិច្ចសន្យាទៅ ជៀសវាងមានបញ្ហាទៅថ្ងៃក្រោយ ហើយគាត់ក៏បានផ្ដិតមេដៃទុកជាភស្តុតាង។ ហើយតាំងពីទិញដីនោះហើយខ្ញុំបានកាន់កាប់ដីនោះរហូតមករយៈពេល១៥ឆ្នាំហើយ។

-មេធាវី [redacted] ធ្វើសេចក្ដីថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុថា កូនក្ដីខ្លួនសូមទាមទារ និងសូមបញ្ជាក់ដូចក្នុងពាក្យបណ្ដឹងរបស់ខ្លួនចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២០ ទុកនៅទាំងស្រុង។ ដោយអង្គហេតុ កាលពីឆ្នាំ២០០៥ កូនក្ដីខ្លួនបានទិញដីពីឈ្មោះ [redacted] មឿន ដែលមានលិខិតទិញលក់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥ និងមានសាក្សីដឹងឮឈ្មោះ [redacted] ម៉េត ដែលត្រូវជាបងប្អូនរបស់ឈ្មោះ [redacted] មឿន បានបញ្ជាក់ថា ឈ្មោះ [redacted] មឿន ពិតជាបានលក់ដីឱ្យកូនក្ដីខ្លួនប្រាកដមែន។ ប៉ុន្តែកូនក្ដីខ្លួនត្រូវការសាលក្រមពីតុលាការ ដើម្បីឱ្យកូនក្ដីខ្លួនចុះបញ្ជីផ្ទេរកម្មសិទ្ធិបាន។ ចំពោះការលក់ទិញទាំងអស់នោះ គឺកូនក្ដីខ្លួនបានប្រគល់លុយឱ្យទៅចុងចម្លើយគ្រប់អស់ហើយ ដូចនេះខ្លួននៅតែរក្សាការទាមទារដូចក្នុងពាក្យបណ្ដឹងរបស់ខ្លួនទុកនៅដដែល និងស្នើសុំឱ្យតុលាការពិនិត្យឯកសារសេចក្ដីបញ្ជាក់របស់សាក្សីខ្លួនឈ្មោះ [redacted] ម៉េត។

-ដើមចោទឈ្មោះ [redacted] សម្បត្តិ ធ្វើការអះអាងនៅក្នុងនីតិវិធីទាញហេតុផលថា ដីហ្នឹងខ្លួនទិញពីម្ដាយមីងកាលពីឆ្នាំ២០០៥ ទិញដីបីប័ណ្ណតម្លៃ ១៤០០ ដុល្លារអាមេរិក។ ហើយការដែលគាត់លក់មកឱ្យខ្លួន គឺមានសាក្សីដឹងឮមានឈ្មោះ [redacted] សុភា និងឈ្មោះ [redacted] ម៉េត។ ដីនោះជាដីស្រែ មានបីស្រែ។ ស្រែពីរមានតម្លៃ ១០០០ ដុល្លារអាមេរិក ហើយមួយស្រែទៀតមានតម្លៃ ៤០០ ដុល្លារអាមេរិក។ ខ្លួនប្រគល់លុយឱ្យទៅឈ្មោះ [redacted] មឿន ពេលហ្នឹងខ្លួនអត់ចេះអក្សរ អត់ដឹងថាត្រូវធ្វើឡើងដល់ភូមិឃុំទេ ដោយសារតែម្ដាយមីងឯង ហើយគាត់ក៏ប្រគល់ប្លង់ទាំងពីរហ្នឹងមកឱ្យខ្លួន ហើយខ្លួនក៏យកមកទុករហូត និងបានធ្វើស្រែលើដីហ្នឹងតាំងពីឆ្នាំ២០០៥ មករហូតដល់សព្វថ្ងៃ។ ខ្លួនធ្វើស្រែនេះរហូតមកគាត់ក៏មិនដែលចេញមុខមកតវ៉ាទេ ទើបមកដល់ពេលនេះ គឺខ្លួនស្នើសុំឱ្យគាត់ផ្ដិតមេដៃផ្ទេរកម្មសិទ្ធិដីហ្នឹងមកឱ្យខ្លួន ប៉ុន្តែគាត់បាននិយាយថា បើខ្លួនលក់ដីហ្នឹង ចាំគាត់ផ្ដិតមេដៃឱ្យ តែបើខ្លួនមិនលក់ដីហ្នឹងទេ គឺអត់ផ្ដិតមេដៃឱ្យខ្លួនទេ។ តាំងពីដើមមកអត់ដែលឈ្លោះគ្នាទេដីហ្នឹង។ ឥឡូវខ្លួននៅតែទទួលស្គាល់

28/4

គាត់ជាម្តាយមីងដដែល។ បានជាខ្លួនធ្វើឡើងមកតុលាការ ពីព្រោះពេលដែលខ្លួនស្នើសុំឱ្យគាត់ផ្តិតមេដៃផ្ទេរកម្មសិទ្ធិមកឱ្យខ្លួន គាត់មិនព្រមផ្តិតឱ្យខ្លួនទេ ហើយគាត់ទារលុយពីខ្លួនពីរម៉ឺនដុល្លារទៀត ប៉ុន្តែគាត់នៅតែថាពេលខ្លួនលក់ដីហ្នឹងទើបបានគាត់ផ្តិតមេដៃឱ្យ។ ខ្លួនមិនចេះអក្សរទេ ខ្លួនអត់ដឹងអ្វីទេ។ ក្រដាស់ស្នាមហ្នឹងគឺពូម៉ាងគាត់ជាអ្នកសរសេរឱ្យ។

៤-១ ការអះអាងរបស់ចុងចម្លើយៈ

-ចុងចម្លើយឈ្មោះ [redacted] មឿន ធ្វើសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទីមួយថា ខ្លួនស្នើសុំឱ្យតុលាការពន្យាពេលឱ្យខ្លួនរយៈពេល ០១ (មួយ) សប្តាហ៍ គិតចាប់ពីថ្ងៃនេះទៅ។ មូលហេតុគឺដោយសារខ្លួនមិនសូវចេះច្បាប់ និងដើម្បីទុកពេលឱ្យខ្លួនស្វែងរកមេធាវីតំណាងឱ្យខ្លួន។

-ចុងចម្លើយឈ្មោះ [redacted] មឿន មានមេធាវីលោក [redacted] ធ្វើសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទីពីរថា នៅក្នុងរឿងក្តីនេះ គឺផុតអាជ្ញាយុកាលហើយ ដូចនេះខ្លួនស្នើសុំឱ្យតុលាការចេញដីកាសម្រេច។

-ចុងចម្លើយឈ្មោះ [redacted] មឿន មានមេធាវីលោក [redacted] ធ្វើសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទីបីថា ខ្លួនសូមប្រានចោលការទាមទាររបស់ដើបចោទចោលទាំងស្រុង ព្រោះថា ប្លង់ដីទាំងបីនោះឈ្មោះ [redacted] មឿន មិនបានយកទៅឱ្យឈ្មោះ [redacted] សម្បត្តិ ទេ គឺឈ្មោះ [redacted] ផល្លីកា ជាអ្នកយកទៅឱ្យឈ្មោះ [redacted] សម្បត្តិ ដើម្បីយកប្រាក់ ត្រង់លក់ផ្តាច់ក្តី ឬបញ្ចាំក្តី ឈ្មោះ [redacted] មឿន មិនបានដឹងទេ។ រីឯលិខិតលក់ផ្តាច់ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥ គឺទើបតែធ្វើក្រោយទេ ប៉ុន្តែយកថ្ងៃខែឆ្នាំចាស់ ។ ហើយក្នុងលិខិតលក់ផ្តាច់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥ ដាក់ដីតែមួយកន្លែងទេ តែគាត់ប្តឹងសុំចំនួនពីរកន្លែង គឺទី១ វិញ្ញាបណ្ណបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបណ្ណបត្រសម្គាល់ម្ចាស់អចលនវត្ថុមួយទៀតលេខ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ នេះជាពាក្យបណ្តឹងរបស់ឈ្មោះ [redacted] សម្បត្តិ ប្តឹងសុំខុសពីកិច្ចសន្យាលក់ផ្តាច់ ដូចនេះខ្ញុំសុំបដិសេធក្នុងពាក្យបណ្តឹងថាឈ្មោះ [redacted] សម្បត្តិ ជាម្ចាស់កម្មសិទ្ធិ ដូចនេះក្នុងរឿងនេះលែងជារឿងរដ្ឋប្បវេណីហើយ វាចូលទៅជារឿងព្រហ្មទណ្ឌហើយ។ តាមមាត្រា ១៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ការបង្អង់នីតិវិធីនៃបណ្តឹង ចំណុចទី៣ ប្រសិនបើរឿងក្តីព្រហ្មទណ្ឌ ដែលមានទាក់ទងនឹងអង្គហេតុ ដែលជាមូលដ្ឋាននៃការទាមទារណាមួយក្នុងរឿងក្តីរដ្ឋប្បវេណីកំពុងត្រូវបានចាត់ការ នោះតុលាការអាចបង្គាប់ឱ្យបង្អង់នៅនីតិវិធីបណ្តឹងរបស់រឿងក្តីរដ្ឋប្បវេណីនោះ ដោយចេញដីកាសម្រេចបាន។ ក្នុងករណីនេះពេលដែលរឿងក្តីព្រហ្មទណ្ឌត្រូវបានបញ្ចប់ តុលាការអាចលុបចោលនូវដីការសម្រេចនោះបាន។ ខ្លួនស្នើសូមឱ្យបង្អង់នីតិវិធីដដែល ព្រោះថាកិច្ចសន្យាលក់ផ្តាច់ទាំងពីរគឺឈ្មោះ [redacted] ម៉ាង ជាអ្នកសរសេរដៃ មិនមែនវាយកុំព្យូទ័រទេ ហើយអក្សរក្នុងកិច្ចសន្យាលក់ផ្តាច់នេះមិនមែនជាអក្សររបស់ឈ្មោះ [redacted] ម៉ាង ទេ ព្រោះក្នុងកិច្ចសន្យាលក់ផ្តាច់នេះមិនមានចុះចំនួនទឹកប្រាក់ទេ តាមច្បាប់កិច្ចសន្យាលក់ផ្តាច់ត្រូវតែចុះចំនួនទឹកប្រាក់ បើមិនមានចុះចំនួនទឹកប្រាក់ទេ គឺត្រូវទុកជាមោឃៈ។

-លោកមេធាវី [redacted] ធ្វើសេចក្តីថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា ខ្លួនសូមជំទាស់នឹងការលើកឡើងរបស់មេធាវីសហភាគា។ ក្នុងនោះលិខិតលក់ដាច់ឱ្យផ្ទេរកម្មសិទ្ធិគឺអត់មានទេ ហើយកាលហ្នឹងឯកសារសរសេរដៃទេ។ ខ្លួនថាហើយនៅក្នុងរឿងនេះមានវិការៈជាច្រើន តែបើចង់ចាញ់ឈ្នះ គឺខ្លួនប្តឹងពីបទព្រហ្មទណ្ឌ តែដោយសារគូភាគីត្រូវជាមីងហើយនឹងក្មួយទើបបន្ថយឱ្យនៅត្រឹមហ្នឹងទៅ។ រឿងកូនរបស់ខ្លួនឈ្មោះ [redacted] ផល្លិកា ទេ ជាអ្នកលក់ដីហ្នឹង យាយហ្នឹងអត់ដឹងអ្វី



Scanned with CamScanner

ទេ។ ចំពោះការចុះបញ្ជីខ្លួនឯកភាព ដោយសារខ្លួនមិនចង់មានរឿងវែងឆ្ងាយ ប៉ុន្តែត្រូវគិតពីតម្លៃបច្ចុប្បន្នមកឱ្យខ្លួន ហើយរឿងចុះបញ្ជីផ្ទេរកម្មសិទ្ធិ និងការបង់ពន្ធជារឿងនៅខាងភូមិបាល មិនមែននៅតុលាការទេ។

-ចុងចម្លើយឈ្មោះ [redacted] មឿន ធ្វើការអះអាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា ខ្លួនអត់ដឹងរឿងទទួលលុយទេ ពីព្រោះកូនខ្លួនវាលក់ ខ្លួនអត់បានទទួលលុយទេថ្លៃលក់ស្រែទាំងពីរហ្នឹងទេ។ ចំពោះស្នាមមេដៃលើលិខិតទិញលក់ខ្លួនអត់បានផ្តិតទេ។ ខ្លួនស្គាល់ឈ្មោះ [redacted] ម៉េត ត្រូវជាប្អូនបង្កើតខ្លួន ហើយឈ្មោះ [redacted] សម្បត្តិ ត្រូវជាក្មួយបង្កើតរបស់ខ្លួន។ ខ្លួនមិនដែលចូលទៅធ្វើស្រែនៅលើដីហ្នឹងទេ ពីព្រោះតាំងពីគេគិតគូរឿងលុយកាក់ជាមួយកូនខ្លួនមក គឺខ្លួនមិនដឹងអ្វីទេ ដោយសារតែកូនខ្លួនវាស្លាប់ហើយ។ ពីមុនគឺខ្លួនធ្វើស្រែនៅលើដីហ្នឹងជាធម្មតា តែតាំងពីឆ្នាំ២០០៥ មក ខ្លួនមិនដឹងថាកូនរបស់ខ្លួនឈ្មោះ [redacted] ផល្លិកា បានលក់ ឬបញ្ចាំដីហ្នឹងឱ្យទៅឈ្មោះ [redacted] សម្បត្តិទេ។ ឥឡូវនេះវាស្លាប់យូរអង្វែងណាស់មកហើយ។ ខ្លួនមានកូនបួននាក់។ ខ្លួនអត់ដែលបានផ្តិតមេដៃលើឯកសារលិខិតទិញលក់ទាំងពីរនេះទេ។ កាលពីដើមឡើយគឺខ្លួនបានធ្វើស្រែជាមួយគ្នារហូតមក។ ខ្លួនអត់ដឹងថាកូនវាលក់ ឬបញ្ចាំទេ ខ្លួនអត់ទាមទារទេ ឈ្មោះ [redacted] សម្បត្តិ ជាអ្នកធ្វើស្រែកលើដីហ្នឹងរហូតមក ខ្លួនខានធ្វើរយៈពេល១៨ឆ្នាំហើយ ខ្លួនអត់ដែលបានធ្វើអ្វីទេ ពីព្រោះមិនដឹងថាកូនវាលក់ ឬបញ្ចាំ សម្រាប់ខ្លួនស្អីក៏មិនដឹងដែរ។ ខ្លួនបានឮហើយ កាលនោះគ្រាន់តែត្រូវរ៉ូវគ្នាទេ ប៉ុន្តែមិនបានទៅធ្វើលិខិតដល់ភូមិដល់ឃុំនោះទេ។

## **សំអាងហេតុ**

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖

១-មូលហេតុនៃការទាមទាររបស់ដើមចោទ មានលក្ខណៈសមស្របដែលអាចឱ្យតុលាការលើកយកមកធ្វើការពិចារណាបាន។

២-នៅក្នុងនីតិវិធីត្រៀម ក៏ដូចជាក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

២-១ ដើមចោទឈ្មោះ [redacted] សម្បត្តិ អះអាងថា ដីនេះជាដីរបស់ខ្លួនបានទិញពីចុងចម្លើយ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥ ដែលមានទីតាំងស្ថិតនៅក្នុងភូមិឈើនាង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ ដោយមានកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥ ប៉ុន្តែមិនបានចុះបញ្ជីផ្ទេរកម្មសិទ្ធិទៅតាមនីតិវិធីច្បាប់នៅឡើយទេ ប៉ុន្តែចុងចម្លើយឈ្មោះ [redacted] មឿន បានឆ្លើយថា ខ្លួនមិនបានដឹងឮ ឬបានផ្តិតមេដៃលើលិខិតទិញលក់ផ្តាច់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥ នោះទេ ចំពោះការឱ្យប្តឹងមកដើមចោទនោះ គឺចុងចម្លើយបានឆ្លើយថា មិនដឹងកូនស្រីរបស់ខ្លួនឈ្មោះ [redacted] ផល្លិកា ដែលបានស្លាប់បាត់នោះយកទៅបញ្ចាំ ឬលក់ឱ្យឈ្មោះ [redacted] សម្បត្តិ នោះទេ។ អង្គហេតុដែលដើមចោទ និងចុងចម្លើយបានលើកឡើង គឺជាអង្គហេតុដែលមានវិវាទ ដូចនេះដើម្បីឱ្យមានភាពច្បាស់លាស់ត្រឹមត្រូវជៀសវាងការវិនិច្ឆ័យដោយគ្មានមូលដ្ឋាន គឺត្រូវទាមទារឱ្យមានភស្តុតាង និងសាក្សីមកបញ្ជាក់ថា ដីនេះ គឺជាដីដែលដើមចោទបានទិញពីឈ្មោះ [redacted] មឿន ពិតប្រាកដ ឬយ៉ាងណា? ហើយឈ្មោះ [redacted] មឿន ពិតជាបានលក់ដីខាងលើនេះឱ្យទៅឈ្មោះ [redacted] សម្បត្តិ ពិតប្រាកដដែរ ឬទេ?

២-២ ឆ្លងតាមលទ្ធផលនៃការសាកសួរសាក្សីឃើញថា៖

២-២-១ សាក្សីឈ្មោះ [redacted] ម៉េត ៖ ថ្វីត្បិតតែសាក្សីមិនបានមកឆ្លើយបំភ្លឺនៅតុលាការ ប៉ុន្តែសាក្សីបានធ្វើលិខិតបំភ្លឺដាក់ជូនតុលាការ ដែលមានខ្លឹមសារថា ខ្លួនឈ្មោះ [redacted] ម៉េត ភេទស្រី អាយុ៧០ឆ្នាំ មានទីលំនៅភូមិឈើនាង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ ខ្លួនពិតជាបានជាបានទទួលដីកាកោះរបស់សាលាដំបូងខេត្តកណ្តាល ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ (សំណុំរឿងរដ្ឋប្បវេណីលេខ ៨៩២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០)

ដើម្បីឱ្យខ្លួនចូលមកសាលសវនាការលេខ ០២ នៃសាលាដំបូងខេត្តកណ្ដាល នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ០៩ ព្រឹក ដើម្បីចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ តែដោយសារពេលបច្ចុប្បន្នខ្លួនមានជំងឺសន្លាក់ធ្ងន់ធ្ងរ និងជរាផង ទើបខ្លួនពុំអាចធ្វើដំណើរទៅធ្វើជាសាក្សីនៅក្នុងសាលសវនាការខេត្តកណ្ដាល នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ នេះបាន។ អាស្រ័យហេតុនេះ ខ្លួនស្នើសុំបំភ្លឺជូនតុលាការថា ខ្លួនពិតជាបានផ្ដិតមេដៃធ្វើជាសាក្សីដឹងឮថា ឈ្មោះ [redacted] មឿន ដែលត្រូវជាស្រីបង្កើតរបស់ខ្លួនពិតជាបានលក់ដីស្រែ ដែលមានវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ ទៅឱ្យឈ្មោះ [redacted] សម្បត្តិ ពិតប្រាកដមែន។

២-៣ ឆ្លងតាមការពិនិត្យភស្តុតាងជាឯកសាររួមមានៈ

២-៣-១ វិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ បញ្ជាក់បានថា ដីទាំងពីរកន្លែងដែលមានទីតាំងស្ថិតនៅភូមិឈើនាង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល គឺពិតជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] មឿន ប្រាកដមែន។

២-៣-២ យោងកិច្ចសន្យាលក់ផ្ដាច់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០ បញ្ជាក់បានថា ឈ្មោះ [redacted] មឿន ភេទស្រី កើតឆ្នាំ១៩៤០ សញ្ជាតិខ្មែរ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្ប[redacted] កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ ០២០០៥៨៤២៦ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០០ បានព្រមព្រៀងគ្នាលក់ដីស្រែមួយកន្លែង មានក្បាលដីលេខៈ ១០ ទំហំ ១៣៧៧ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹង [redacted] សួង (ក្បាលដីលេខៈ ១២) ខាងត្បូងទល់នឹង ភ្លឺស្លោះ ខាងកើតទល់នឹង [redacted] ចាន់ថន (ក្បាលដីលេខៈ១១) ខាងលិចទល់នឹង [redacted] ចន (ក្បាលដីលេខ៩) ដែលមានទីតាំងស្ថិតនៅភូមិឈើនាង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ឱ្យទៅឈ្មោះ [redacted] សម្បត្តិ ភេទស្រី កើតឆ្នាំ១៩៦៧ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន[redacted] កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០២០០៥៨០៨៤ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០០ ដើម្បីកាន់កាប់បន្តចាប់ពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥ ប្រាកដមែន។

២-៣-៣ យោងកិច្ចសន្យាលក់ផ្ដាច់ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០ បញ្ជាក់បានថា ឈ្មោះ [redacted] មឿន ភេទស្រី កើតឆ្នាំ១៩៤០ សញ្ជាតិខ្មែរ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្ប[redacted] កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ ០២០០៥៨៤២៦ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០០ បានព្រមព្រៀងគ្នាលក់ដីស្រែមួយកន្លែង មានក្បាលដីលេខៈ ៥៨ ទំហំ ២៤៨៦ ម៉ែត្រការ៉េ មានព្រំប្រទល់ខាងជើងទល់នឹង [redacted] ចាន់ថុន (ក្បាលដីលេខ៥៩) ខាងត្បូងទល់នឹង [redacted] ចាន់ថុល (ក្បាលដីលេខ៥៦) ខាងកើតទល់នឹង [redacted] សុគន់ (ក្បាលដីលេខ៦២) ខាងលិចទល់នឹង ទំរទឹក ដែលមានទីតាំងស្ថិតនៅភូមិឈើនាង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ឱ្យទៅឈ្មោះ [redacted] សម្បត្តិ ភេទស្រី កើតឆ្នាំ១៩៦៧ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន[redacted] កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០២០០៥៨០៨៤ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០០ ដើម្បីកាន់កាប់បន្តចាប់ពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៥ ប្រាកដមែន។

២-៣-៤ យោងលិខិតបញ្ជាក់លេខ ១៤/២០២១.ប.ជ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ របស់មេឃុំគោកត្រប់ បញ្ជាក់ថា ឈ្មោះ [redacted] មឿន ភេទស្រី កើតឆ្នាំ១៩៤០ នៅ[redacted] បានកាន់កាប់ដីទំហំ ២៤៨៦ ម៉ែត្រការ៉េ និងទំហំ ១៣៧៧ ម៉ែត្រការ៉េ តាំងពីឆ្នាំ២០០៥ រហូតដល់រដ្ឋចែក និងធ្វើវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ ចេញដោយ



Scanned with CamScanner

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្តាល។ ហើយនៅឆ្នាំ២០០៥ បានឃើញឈ្មោះ ទេព សម្បត្តិ ភេទស្រី កើតឆ្នាំ១៩៦៧ នៅភូមិឈើនាង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បានធ្វើស្រែនៅលើដីនោះរហូតមកដល់បច្ចុប្បន្ន។

៣-ឆ្លងតាមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នីតិវិធីសាកសួរសាក្សី និងនីតិវិធីពិនិត្យភស្តុតាង ឃើញថា ដើមចោទអះអាងថាដីនេះជាដីរបស់ខ្លួនដែលបានទិញពីឈ្មោះ [redacted] មឿន តាំងពីថ្ងៃទី២៦ ខែមេសាឆ្នាំ២០០៥ មកហើយ ប៉ុន្តែមិនទាន់បានធ្វើការចុះបញ្ជីកាត់ឈ្មោះនៅឡើយទេ ហើយចុងចម្លើយឈ្មោះ [redacted] មឿន ថាមិនបានលក់ដីខាងលើនេះឱ្យទៅដើមចោទទេ។ យោងតាមការសាកសួរសាក្សីដូចមានក្នុងចំណុចទី ២-២-១និងតាមការពិនិត្យភស្តុតាងជាឯកសារដូចមានក្នុងចំណុចទី ២-៣-១, ២-៣-២, ២-៣-៣ និងចំណុចទី ២-៣-៤ គឺអាចបញ្ជាក់បានថា ដីដែលជាកម្មវត្ថុនៃការទាមទាររបស់ដើមចោទខាងលើនេះ គឺជាដីរបស់ដើមចោទដែលបានទិញពីឈ្មោះ [redacted]មឿន ប៉ុន្តែមិនទាន់បានធ្វើការកាត់ឈ្មោះតាមនីតិវិធីរបស់មន្ទីរជំនាញនៅឡើយទេ ដូចនេះគប្បីតុលាការទទួលស្គាល់ដីដែលមានវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ មានទីតាំងស្ថិតនៅភូមិឈើនាង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល គឺជាកម្មសិទ្ធិរបស់ដើមចោទ ឈ្មោះ [redacted] សម្បត្តិ និងបង្គាប់ឱ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនូវអចលនវត្ថុជាដីស្រែទាំងពីកន្លែង ដែលមានទីតាំងស្ថិតនៅក្នុងភូមិឈើនាង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មានវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ មកឱ្យដើមចោទឈ្មោះ[redacted]សម្បត្តិ។

៤-ប្រាក់ពន្ធត្រូវសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**សេចក្តីសម្រេចបញ្ចប់**

១-ទទួលស្គាល់ដើមចោទឈ្មោះ [redacted] សម្បត្តិ ភេទស្រី កើតឆ្នាំ១៩៦៧ មានអត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិនូវដីទាំងពីរកន្លែង ដែលមានទីតាំងស្ថិតនៅក្នុងភូមិឈើនាង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មានវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥។

២-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] មឿន ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនូវអចលនវត្ថុជាដីស្រែទាំងពីកន្លែង ដែលមានទីតាំងស្ថិតនៅក្នុងភូមិឈើនាង ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មានវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៨០១០៩០៧-០០១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ និងវិញ្ញាបនប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០៩០៧-០០៥៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៥ មកឱ្យដើមចោទឈ្មោះ[redacted]សម្បត្តិ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយឈ្មោះ [redacted]មឿន។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណាត់ច្បាប់។

ចៅក្រម

[redacted]



Scanned with CamScanner